# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២២*

## សេចក្តីប្រកាសព័ត៌មានរួម
## ស្តីពី
## សិក្ខាសាលាផ្សព្វផ្សាយស្តីពី
## "វេបផតថលសម្រាប់ធុរកិច្ច និង សេដ្ឋកិច្ចឌីជីថលកម្ពុជា"

ក្រោយការដាក់អនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ កាលពី ខែ ឧសភា ឆ្នាំ ២០២១ កន្លងទៅ, រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តគោលនយោបាយគន្លឹះក្នុងការផ្តល់ព័ត៌មានពិតឱ្យបានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយ ស្តីពីដំណើររបស់កម្ពុជាឆ្ពោះទៅកាន់សេដ្ឋកិច្ច និងសង្គមឌីជីថល តាមរយៈវេបផតថល និងមធ្យោបាយផ្សព្វផ្សាយនានា ។ ជាក់ស្តែង, នារសៀលថ្ងៃទី **២៧ ខែ តុលា ឆ្នាំ ២០២២**, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងក្រុមហ៊ុន Meta បានសហការរៀបចំសិក្ខាសាលាស្តីពី **"វេបផតថលសម្រាប់ធុរកិច្ច និង សេដ្ឋកិច្ចឌីជីថលកម្ពុជា"** នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (Hyatt Regency Phnom Penh Hotel)។ សិក្ខាសាលានេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដោយមានការចូលរួមពីតំណាងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, វិស័យឯកជន, សមាគម និងសង្គមស៊ីវិល សរុបប្រមាណ **១២០** រូប។

សិក្ខាសាលានេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅកាន់វិស័យឯកជន និងវិស័យសាធារណៈ ក៏ដូចជាលើកទឹកចិត្តឱ្យសាធារណជនប្រើប្រាស់នូវវេបផតថល និងគេហទំព័រសំខាន់ៗ ពាក់ព័ន្ធនឹងធុរកិច្ច និងសេដ្ឋកិច្ចឌីជីថល ដែលមានដូចជា ៖

**(១) គេហទំព័ររបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** (www.digitaleconomy.gov.kh) ដាក់បង្ហាញនូវសកម្មភាពការងាររបស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ទិន្នន័យ ថ្នាលឌីជីថល និងគម្រោងគាំទ្រសំខាន់ៗពាក់ព័ន្ធនឹងវិស័យដែលគាំទ្រដល់សេដ្ឋកិច្ច និងសង្គមឌីជីថល។

(២) **ច្រកចេញចូលធុរកិច្ច** (www.business.gov.kh) ប្រមូលផ្តុំព័ត៌មានស្តីពីការធ្វើធុរកិច្ចនៅកម្ពុជា ដាក់ក្នុងកន្លែងតែមួយ សម្រួលដល់ធុរជនក្នុងការស្វែងរកព័ត៌មានស្តីពីការស្នើសុំវិញ្ញាបនបត្រ, អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងកិច្ចការងារផ្សេងៗទៀតក្នុងការធ្វើធុរកិច្ចនៅកម្ពុជា។

(៣) **ច្រកចេញចូលធុរកិច្ចថ្មីកម្ពុជា** (www.startupcambodia.gov.kh) ជាផ្នែកមួយនៃកម្មវិធីថ្នាក់ជាតិធុរកិច្ចថ្មីកម្ពុជា បង្កើតឡើងដើម្បីរៀបបញ្ជីនៃតួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីកម្ពុជាសំដៅបង្កើនអន្តរសកម្មរវាងតួអង្គគាំទ្រធុរកិច្ចថ្មី និងប្រព័ន្ធអេកូឡូស៊ីឲ្យកាន់តែមានភាពប្រទាក់ក្រឡា និងរស់រវើក។

(៤) **គម្រោង Go4eCam** ផ្តល់នូវវគ្គឧណ្តាចាំបាច់ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការធ្វើបរិវត្តកម្មឌីជីថល និងទទួលបានសិទ្ធិប្រើប្រាស់ថវិកាតាមតម្រូវការ ក្នុងការចាប់យកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើអាជីវកម្មឱ្យមានលក្ខណៈផ្លូវការ ដើម្បីគាំទ្រដល់ការត្រៀមខ្លួនក្នុងការនាំចេញ។

ទន្ទឹមនេះ, សិក្ខាសាលាក៏បានផ្សព្វផ្សាយពី**វេបផតថលសេដ្ឋកិច្ចឌីជីថល** (www.dep.kh) ដែលជាវេបផតថលផ្តល់ព័ត៌មានស្តីពីសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលរៀបចំឡើងដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ ក្រោមកិច្ចសហការជាមួយក្រុមហ៊ុន Meta ផងដែរ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដែលបានមើលឃើញពីសារៈសំខាន់, សក្តានុពល និងកាលានុវត្តភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងជំរុញធុរកិច្ចឌីជីថលនៅប្រទេសកម្ពុជា ដែលក្នុងនោះការទទួលបានទិន្នន័យ និងព័ត៌មានគ្រប់ជ្រុងជ្រោយ និងអាចទុកចិត្តបាន ពីសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល តាមរយៈវេបផតថល និងមធ្យោបាយផ្សព្វផ្សាយខាងលើ មានសារៈសំខាន់ក្នុងការជំរុញការចាប់យកឌីជីថល និងបរិយាប័ន្នឌីជីថល និងលើកស្ទួយការយល់ដឹងពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងដំណើរនៃការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលរស់រវើក និងប្រកបដោយបរិយាប័ន្ន។ ទន្ទឹមនេះ, ការរៀបចំសិក្ខាសាលានេះឡើងបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីសារៈសំខាន់នៃសហថាមពល (Synergy) ដែលកើតឡើងរវាងកិច្ចសហប្រតិបត្តិការ និងវិស័យរដ្ឋ និងឯកជន ក្នុងការជំរុញឱ្យមានការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថលនៅលើគ្រប់វិស័យ និងតួអង្គ។

សិក្ខាសាលានេះបានប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុកថែមទាំងទទួលបានធាតុចូលល្អៗជាច្រើន តាមរយៈការពិភាក្សា, ការចែករំលែកទស្សនាទាន, គំនិតនវានុវត្តន៍ និងបទពិសោធន៍ជាក់ស្តែងពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

**Nation Religion King**

*Phnom Penh, October 27, 2022*

# Press Release
# Workshop on
# Cambodia's Digital Economy and Business Web Portals

Following the implementation of the Digital Economy and Society Policy Framework in May 2021, the Royal Government has begun to set forth policy measures to provide factual and comprehensive information on Cambodia's journey toward a digital economy and society through web portals and other publication channels. On **October 27, 2022**, the Digital Economy and Business Committee, Techo Startup Center, and Meta company co-organized the workshop on "Cambodia's Digital Economy and Business Web Portals" at Hyatt Regency Phnom Penh Hotel. This workshop was presided over by **His Excellency Dr. Kong Marry**, Under Secretary of State of the Ministry of Economy and Finance and Secretary General of the General Secretariat of the Digital Economy and Business Committee, with the participation of around 120 representatives from the Digital Government Committee, relevant ministries and institutions, private sector, associations, and civil society.

The workshop aims disseminate information to the public and private sectors as well as urge the public to use essential web portals and websites related to digital business and economy, including:

(1) **The Digital Economy and Business Committee website** (www.digitaleconomy.gov.kh) displays activities of the Digital Economy and Business Committee, data, digital platforms, and important projects related to sectors that support the digital economy and society.

(2) **The business platform** (www.business.gov.kh) is a central hub that gathers all information about doing business in Cambodia, making it easier for businesses to access

information related to requesting business certificates, licenses, and permits and doing business in Cambodia.

(3) **Startup Cambodia platform** (www.startupcambodia.gov.kh) is a part of the National Startup Cambodia Program that compiles a list of stakeholders in Cambodia's startup ecosystem with the aim to increase interaction between startup support stakeholders and the ecosystem to become more interconnected and vibrant.

(4) **The E-Commerce project** (Go4eCam) provides the necessary conditions for MSMEs to go digital and gain access to much-needed finance for e-commerce uptake and business formalization to support export readiness.

In addition, the workshop also disseminated information related to **the Digital Economy Web Portal** (www.dep.kh), a web portal that provides information on the digital economy and society in Cambodia. The web portal is a collaborative work between Open Development Cambodia and Meta company.

This workshop was organized in alignment with the advice of **His Excellency Akka Pundit Sopheacha AUN Pornmoniroth,** Deputy Prime Minister, Minister of Economy and Finance, who sees the importance, potentials and opportunities of using digital technologies in the development of digital economy and the promotion of digital business in Cambodia, in which accessing comprehensive and trustworthy data, information, and activities of the digital economy and business through web portals and media platforms is essential in promoting digital adoption and the digital inclusion and promoting the knowledge about the use of digital technologies. Furthermore, today's workshop distinctly reflects the importance of synergy between the public and private sectors in promoting digital adoption and digital transformation in all sectors and of all actors.

As a result, the workshop ran smoothly and achieved expected outputs and useful inputs through the lively discussion and the sharing of innovative ideas and experiences.